# ឧស្សាហកម្មជួញដូរផ្លូវភេទកុមារនៃប្រទេសកម្ពុជាកំពុងថយចុះ ហើយសូមអរគុណដល់ក្រុមស្ថាប័នគ្រិស្តបរិស័ទ

ចាប់ពីការងារផ្នែកជួយសង្គ្រោះរហូតដល់ការកែទម្រង់ផ្នែកច្បាប់ ក្រុមគ្រិស្តបរិស័ទ ដែលស្មោះត្រង់មួយក្រុម បានផ្លាស់ប្តូរទិដ្ឋភាពផ្នែកព្រហ្មទណ្ឌនៃប្រទេសកម្ពុជា។

រៀបរៀងដោយ Kate Shellnutt ពីរាជធានីភ្នំពេញ
រូបថតដោយ Claire Eggers

លោក សេក សារឿន បានអានព្រះគម្ពីរជាលើកដំបូងនៅក្លឹបមួយកន្លែងក្នុងទីក្រុងភ្នំពេញ ដែលមានស្ត្រីៗ វ័យក្មេងត្រូវបានគេលក់ដូរសម្រាប់ផ្លូវភេទខុសច្បាប់។ នំហាំប៊ឺហ្គឺរមួយតម្លៃ $១.00 ស្រាបៀរមួយកែវតម្លៃ $១.៥0 ហើយគេអាចរកដៃគូកំដរមួយរាត្រីបាន បើអតិថិជនចំណាយប្រាក់ច្រើនជាងនេះ។

និស្សិតផ្នែកច្បាប់ម្នាក់ ដែលកាន់ព្រះពុទ្ធសាសនាបានបម្រើការជាអ្នកចាក់ចម្រៀងនៅក្នុងក្លឹបម៉ាទីនី ហើយថ្មីៗនេះ គាត់បានចាប់ចូលបម្រើការងារជាអ្នកយកការណ៍សម្ងាត់ឱ្យក្រុមអង្គការសិទ្ធិមនុស្សគ្រិស្តបរិស័ទ មួយឈ្មោះថា បេសកកម្មយុត្តិធម៌អន្តរជាតិ (ហៅកាត់ថា IJM)។ គាត់បានពិនិត្យមើលនៅក្នុងបន្ទប់ ដើម្បី រកមើលជនសង្ស័យនៅខណៈពេលដែលបទចម្រៀងរបស់លោក Michael Jackson ត្រូវបានចាក់ឮៗចេញ ពីឧបករណ៍បំពងសំឡេង។ ដោយសារតែអង្គការ IJM បានណែនាំ ហើយធ្វើឱ្យគាត់ចង់ដឹងចង់ឮថែមទៀត គាត់បានបើកព្រះគម្ពីរដែលខ្ចីពីគេ ហើយក៏ចាប់ផ្តើមអានព្រះគម្ពីរនោះនៅក្នុងបន្ទប់ចាក់បទចម្រៀង។

លោកសារឿន បានចូលរួមក្នុងការស៊ើបអង្កេតពីការជួញដូរផ្លូវភេទដំបូងបង្អស់របស់អង្គការ IJM ក្នុង ប្រទេសកម្ពុជា។ ប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍មួយនេះ បានប្រែក្លាយជាកន្លែងប្រព្រឹត្តអំពើស្មោគគ្រោគ ដែលធូរថ្លៃសម្រាប់ទេសចរណ៍ផ្លូវភេទអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ បន្ទាប់ពីរបបប្រល័យពូជ សាសន៍ដ៏ឃោរឃៅ ហើយដែលធ្វើឱ្យមានជម្លោះវឹកវរក្នុងប្រទេស។ នៅឆ្នាំ ២00៣ អង្គការ IJM បានចាប់ផ្តើមកិច្ចខិតខំប្រឹងប្រែងបែបទ្រង់ទ្រាយធំដំបូងបង្អស់ ដើម្បីជួយដោះស្រាយបញ្ហាផ្នែកប្រព័ន្ធយុត្តិធម៌ សាធារណៈក្នុងប្រទេសកម្ពុជា ដែលបានបណ្តែតបណ្តោយឲ្យមេបន និងអ្នកដែលចូលចិត្តរួមភេទជាមួយកុមារ រួចខ្លួនបាន។

ដោយមានអារម្មណ៍រំភើបផង ខ្មើមឆ្មើមផង និងភ័យខ្លាចគេចាប់ខ្លួនផង ខណៈពេលស៊ើបការណ៍នៅក្នុងទីក្រុង ភ្នំពេញ លោកសារឿន បានទន្ទេញខគម្ពីរ រ៉ូម ១២:១២ *"ចូរសប្បាយរីករាយដោយចិត្តសង្ឃឹម។ ចូរកាន់ចិត្ត អត់ធ្មត់ក្នុងពេលមានទុក្ខលំបាក។ ចូរព្យាយាមអធិស្ឋាន"*។ លោកបានថ្លែងប្រាប់មិត្តរួមការងារនៅក្នុងសន្និបាត របស់អង្គការ IJM នាពេលមួយទសវត្សរ៍ក្រោយមក ដោយពន្យល់ពីរបៀបដែលលោកបានក្លាយជាគ្រិស្តបរិស័ទ និងជាមេធាវីផ្តើមនៃក្រុមអង្គការសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាថា៖ "ភាពភ័យខ្លាចធ្វើឱ្យមានបំណងចង់បាន ហើយបំណងចង់បានធ្វើឱ្យមានការផ្លាស់ប្រែ ដែលលើសពីការគិត"។

លោកសារឿន មានប្រសាសន៍បន្តថា៖ "ព្រះជាម្ចាស់មិនគ្រាន់តែបានផ្លាស់ប្រែខ្ញុំប៉ុណ្ណោះទេ ទ្រង់ក៏បាន ផ្លាស់ប្រែក្រុមគ្រួសារ សហគមន៍ និងប្រជាជាតិផងដែរ"។

នៅរវាងឆ្នាំ ២00៤ និង ២0១៥ លោកសារឿន និងក្រុមការងារគាត់បានមើលឃើញពីភាពកើតឡើង ជាធម្មតានៃក្មេងស្រីមិនទាន់គ្រប់អាយុ ដែលធ្វើការនៅតាមផ្ទះបន ដែលមានមនុស្សអ៊ូអរ ហាងម៉ាស្សាតាមដង

ផ្លូវ និងក្លឹបខារ៉ាអូខេ ដែលបំពាក់ភ្លើងពណ៌ចម្រុះ បានធ្លាក់ចុះបន្តិចម្តងៗក្នុងអំឡុងពេលដែលពួកគេបានធ្វើការងារជាដៃគូជាមួយក្រុមនគរបាលប្រឆាំងការជួញដូរ និងសេវាសង្គមនៃប្រទេសកម្ពុជា ដើម្បីជួយរំដោះជនរងគ្រោះជាង ៥០០នាក់ និងព្រមទាំងនាំបណ្តឹងលើករណីជួញដូរផ្លូវភេទកុមារប្រហែលជា ១៤០ករណីឡើងដល់តុលាការ។ ការសិក្សាស្រាវជ្រាវរបស់អង្គការ IJM បានបង្ហាញថា នៅឆ្នាំ២០១៥ មានស្ត្រីតែ ២%ប៉ុណ្ណោះមានអាយុតិចជាង ១៨ឆ្នាំ ដែលត្រូវបានជួញដូរនៅក្នុងផ្ទះបន និងកន្លែងកំសាន្តបែបអាជីវកម្មផ្លូវភេទនៅក្នុងទីក្រុងភ្នំពេញ ក្រុងសៀមរាប និងក្រុងព្រះសីហនុ។ នៅពេលអង្គការនេះបានធ្វើការសិក្សាស្រាវជ្រាវជុំដំបូងកាលពីឆ្នាំ ២០១២-២០១៣ នោះ លទ្ធផលនេះមានចំនួនច្រើនជាង ៤ដង។ ហើយនៅពេលរដ្ឋាភិបាលកម្ពុជាបានប៉ាន់ប្រមាណនៅដើមឆ្នាំ ២000 មន្ត្រីរដ្ឋាភិបាលបាននិយាយថា ស្ត្រី ដែលមានអាយុក្រោម ១៨ឆ្នាំធ្លាប់មានចំនួនដល់ទៅ ៣0% នៃចំនួនស្ត្រី ដែលបម្រើសេវាផ្លូវភេទនៅក្នុងផ្ទះបន។

ជនបរទេស ដែលមានសក់ស្កូវជិះម៉ូតូដួល ជួនកាលនៅតែធ្វើដំណើរមកកាន់តំបន់ស្វាយប៉ាក ដែលជាតំបន់ជាយក្រុង មានធូលីហុយ និងជាតំបន់ ដែលស្ត្រីវ័យក្មេងអាយុក្រោម ១០ឆ្នាំធ្លាប់បានប្រគល់ខ្លួនទៅឲ្យបុរសបរទេសស្បែកសនៅតាមដងផ្លូវ។ ប៉ុន្តែឥលូវនេះ ពួកគេរំពឹងថា នឹងមិនមានការប្រព្រឹត្តសកម្មភាពដូចគ្នាពីមុនទៀតនោះឡើយ។

នៅតាមដងផ្លូវ ដែលធ្លាប់មានហាងតូចៗ អង្គការមេត្រីអន្តរជាតិ (AIM) បានយកផ្ទះបនទាំងនោះដែលត្រូវបានបង្ក្រាបដោយអង្គការ IJM ទៅប្រែក្លាយជាក្រុមជំនុំ គ្លីនិក មណ្ឌលស្តារនិតិសម្បទា និងរោង ចក្រកាត់ដេរ ដើម្បីព្យាយាមស្តារតំបន់ ដែលធ្លាប់មានរឿងអសោចនេះ ឱ្យមានភាពស្រស់ប្រសើរឡើងវិញ។

លោក ផល សុគន្ធី ដែលបានធំដឹងក្តីឡើងនៅតំបន់ស្វាយប៉ាក ហើយឥលូវបម្រើការងារជាអ្នកជំនួយការផ្នែកប្រតិបត្តិម្នាក់នៅអង្គការ AIM ដែលមានបុគ្គលិក ៣00នាក់នៅទីនោះ បាននិយាយថា៖ "ខ្ញុំបានឃើញសហគមន៍នេះផ្លាស់ប្រែ។ មនុស្សម្នាធ្លាប់និយាយថា កន្លែងនេះជាកន្លែងអាស្រូវកខ្វក់ជាងគេនៅក្នុងស្រុកខ្មែរ"។ លោក សុគន្ធី អ្នករស់នៅជិតខាង និងជនរួមជាតិជាមួយលោកជាច្រើននាក់ទៀតត្រូវតែ "មានចិត្តអត់ធ្មត់នៅក្នុងទុក្ខលំបាក" ពេញមួយជីវិតរបស់ពួកគេ។ បន្ទាប់ពីឆ្នាំ ១៩៧៥ ដែលត្រូវបានប្រកាសថាជាឆ្នាំសូន្យដោយសាររបបបដិវត្តន៍កុម្មុយនីស្តខ្មែរក្រហម ដែលបានកាន់កាប់រដ្ឋាភិបាលកម្ពុជា ប្រជាជននៅតាមទីក្រុងនានាក្នុងប្រទេសកម្ពុជាត្រូវបានជម្លៀសខ្លួនចេញ ហើយមនុស្សជាង ១.៧ លាននាក់ត្រូវបានសម្លាប់ (ជាង២០% នៃចំនួនប្រជាជនសរុប) នៅក្នុងការប្រល័យពូជសាសន៍ប្រឆាំងនឹងបញ្ញាវន្ត និងបព្វជិត ព្រមទាំងបង្ខំអ្នករស់រានមានជីវិតឲ្យរត់ភៀសខ្លួនទៅកាន់ជំរំនៅតាមជាយដែន ខណៈពេលភាពរីករវបានផ្ទុះឡើងនៅក្នុងប្រទេស។

ហេតុនេះហើយ ជំនាន់ ដែលប៉ះទង្គិចអារម្មណ៍ផ្លូវចិត្តក្នុងនៅសេដ្ឋកិច្ចដុនដាបនេះ បានបង្កលក្ខណៈអំណោយផលដល់អំពើកេងប្រវ័ញ្ចនៅតាមតំបន់ស្រុកស្រែចម្ការ រោងចក្រ និងផ្ទះបនពេស្យា។ ប៉ុន្តែដោយយោងតាមបទសម្ភាសន៍ជាមួយអ្នកដឹកនាំក្រុមជំនុំកម្ពុជា មន្ត្រីផ្នែកសង្គមកិច្ច មន្ត្រីរដ្ឋាភិបាល និងជនរួចផុតពីការជួញដូរបានបង្ហាញពីទិដ្ឋភាព ដែលផ្លាស់ប្តូរនាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានវឌ្ឍនភាពយ៉ាងខ្លាំងដែលបានដឹកនាំដោយក្រុមស្ថាប័នគ្រិស្តបរិស័ទ។ ពួកគេមើលឃើញពីរូបភាពនៃក្តីសង្ឃឹមនៅក្នុងកន្លែងមួយចំនួនដ៏ខ្មៅងងឹតបំផុតនៅក្នុងប្រទេស។

## លើសពីការជួយសង្គ្រោះ

រថយន្តកងកម្លាំងនគរបាលសម្រុកចូលទៅក្នុងផ្ទះស័ង្កសីពណ៌បៃតងមួយនៅខាងមុខអគារប៊ូលឌីញ ដែលជាគម្រោងសាងសង់លំនៅដ្ឋានមួយកន្លែងនៅក្នុងទីក្រុងភ្នំពេញ ដែលផ្នែកខាងមុខនៃអគារដ៏ងងឹតអាប់អួរនេះបានលាក់ទុកសិល្បៈករក្រីក្រ អ្នករកស៊ីផ្លូវភេទ និងអ្នកជួញដូរគ្រឿងញៀនខុសច្បាប់។

ការចុះបង្ក្រាបលើកដំបូងរបស់ប៉ូលីសប្រឆាំងការជួញដូរនៅក្នុងបរិវេណអគារដែលមានឈ្មោះអាស្រូវនេះ បានឈានដល់ការឃាត់ខ្លួនស្ត្រីបីនាក់ ដែលជាមេបនពេស្យាមួយកន្លែង។ នៅខណៈពេលមន្ត្រីនគរបាលកំពុងប្រមូលភ័ស្តុតាង ស្ត្រីទាំងបីនាក់នោះត្រូវបានដាក់ខ្នោះដៃឱ្យអង្គុយចុះនៅលើសាឡុងក្នុងបន្ទប់តូចមួយ ដែលជាផ្លូវនាំទៅបន្ទប់មួយទៀតនៅខាងក្រោយ និងជាផ្លូវនាំទៅបន្ទប់ពីរទៀតនៅខាងលើ ដោយឡើងតាមជណ្តើរឈើ។ បន្ទប់នីមួយៗមានគ្រែមួយ តុដំណេកដាក់អំពូលភ្លើង និងពិដានទាបខ្លាំង ដែលភ្ញៀវចូលមកត្រូវតែអោន ដើម្បីចូលទៅខាងក្នុង។

នៅក្នុងសម្លៀកបំពាក់លេចស្មាព្រាលៗ និងប៉ាក់ដោយជ័រផ្លេកៗ ក្មេងស្រីមិនទាន់គ្រប់អាយុចំនួនប្រាំមួយនាក់ ដែលធ្វើការនៅទីនោះ បានដើរចូលក្នុងរថយន្តពណ៌សមួយគ្រឿង ដែលសំដៅទៅកាន់ប៉ុស្តិ៍ប៉ូលីស។ មន្ត្រីសង្គមកិច្ចនៃអង្គការ AIM បានជិះអម និងនៅជាមួយពួកគេពេញមួយយប់ ដើម្បីធានាថា ជនរងគ្រោះទាំងនោះគ្មានបញ្ហាអ្វីកើតឡើង ហើយព្រមទាំងពន្យល់ពួកគេអំពីមណ្ឌលសុវត្ថិភាព ដែលជាជម្រើសសម្រាប់ពួកគេ។

ភាគច្រើន ក្មេងស្រីទាំងនេះមិនដឹងពីថ្ងៃកំណើតពិតប្រាកដរបស់ខ្លួននោះទេ គឺដឹងត្រឹមតែតំណាងសត្វនៃឆ្នាំដែលខ្លួនកើតមកតែប៉ុណ្ណោះ។ ក្មេងស្រីដែលមានវ័យក្មេងជាងគេ ដែលត្រូវបានរំដោះនៅយប់នោះបានកើតនៅឆ្នាំមមី (សេះ) ដែលមានន័យថា នាងអាយុ ១៣ ឬ ១៤ឆ្នាំ។ ការចុះបង្ក្រាបបែបនេះ ហាក់ដូចជាការបញ្ជាក់ពីសារៈសំខាន់នៃចំណាប់អារម្មណ៍ថ្មីៗរបស់អ្នកជឿសាសនាគ្រិស្តប៉ែកខាងសហរដ្ឋអាមេរិក ចំពោះការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សជាសកល ដែលជនល្មើសត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារ ហើយជនរងគ្រោះវ័យក្មេងត្រូវបានរំដោះឲ្យមានសេរីភាព។ ប៉ុន្តែភាពពិតជាក់ស្តែងនៅប្រទេសកម្ពុជា ដែលទទួលបានលំដាប់លេខ ៣ លើពិភពលោកសម្រាប់អំពើទាសភាពសម័យទំនើប ពិតជាមិនស្របគ្នាទៅនឹងការសន្និដ្ឋានរបស់ប្រជាជននៅលោកប៉ែកខាងលិចភាគច្រើននោះឡើយ។

លោក Andy Blalock មានប្រសាសន៍ថា៖ "ប្រជាជននៅប៉ែកលោកខាងលិចគិតថា រាល់អំពើជួញដូរទាំងអស់ គឺមានស្ត្រីត្រូវបានគេឃុំចាប់ចង។ ប៉ុន្តែវាជាការចាប់ចងបែបអរូបី និងគំនាបពីក្រុមគ្រួសារទៅវិញទេ"។ លោក Andy គឺជាប្រធានផ្នែកស៊ើបអង្កេតនៃក្រុមការងារជួយសង្គ្រោះរបស់អង្គការ AIM ដែលមានឈ្មោះហៅក្រៅថា "ក្រុមជួយសង្គ្រោះ" ដែលបានសហការជាមួយក្រុមប៉ូលីស ដើម្បីធ្វើការចុះបង្ក្រាបនៅអគារប៊ូលឌីញ ក៏ដូចជានៅទីតាំងជាច្រើនទៀតកាលពីឆ្នាំមុននេះ។

នៅក្នុងប្រទេសកម្ពុជា ស្ត្រីវ័យក្មេងជាច្រើនប្រកបរកស៊ីរបរផ្លូវភេទ ដោយមានការយល់ព្រម ឬការជំរុញពីក្រុមគ្រួសារ និងមិត្តភក្តិរបស់គេ ដើម្បីជារបៀបក្នុងការរកប្រាក់ចំណូល។ នៅតាមដងវិថីដ៏មមាញឹកដែលមានហាងខារ៉ាអូខេ និងបៀរហ្គាឌិន អ្នកធ្វើដំណើរកាត់ទីនោះអាចមើលឃើញមិត្តប្រុសជូនមិត្តស្រីមកដល់កន្លែងធ្វើការ។ នៅពេលជនបរទេសនៅលោកខាងលិច ដែលមានចិត្តអាណិតអាសូរ បានដឹងថាឧស្សាហកម្មផ្លូវភេទមានកុមារប្រមាណជាង ២លាននាក់នៅជុំវិញពិភពលោក ពួកគេជាច្រើនគិតថា ដើម្បីបញ្ឈប់ការជួញដូរផ្លូវភេទ ព័ន្ធកិច្ចគ្រិស្តបរិស័ទត្រូវតែរំដោះកុមារទាំងនោះឲ្យមានសេរីភាព។ ប៉ុន្តែក្រុមអ្នកដឹកនាំ

គ្រិស្តបរិស័ទនៃចលនាលុបបំបាត់អំពើជួញដូរមនុស្សសម័យទំនើបនៅក្នុងប្រទេសកម្ពុជាវិញ ជំរុញឲ្យមនុស្សយល់ដឹងកាន់តែទូលំទូលាយជាងមុន គឺថាជោគជ័យនេះមិនមានន័យថា ជាការរំដោះកុមារឱ្យមានសេរីភាពនោះទេ។

អ្នកស្រី Helen Sworn មានប្រសាសន៍ថា៖ "ការជួយរំដោះ គឺជាព្រឹត្តិការណ៍កើតឡើងតែម្តង។ អ្នកអាចរំដោះស្ត្រី ២០នាក់ចេញពីផ្ទះបនបាន ប៉ុន្តែផ្ទះបននោះនឹងនាំយកស្ត្រី ២០នាក់មកថែមទៀត"។ អ្នកស្រី Helen គឺជាស្ថាបនិកនៃអង្គការសម្ព័ន្ធចាប់ដៃ ដែលជាសម្ព័ន្ធនៃអង្គការជាង ៥០ស្ថាប័ន ដែលរួបរួមគ្នាធ្វើការងារបង្ការ និងស្តារជនរងគ្រោះដោយអំពើជួញដូរនៅទូទាំងប្រទេសកម្ពុជា។ អ្នកស្រីបានបន្តទៀតថា៖ "វាមិនមែនជាបញ្ហាត្រឹមតែពីរទៅបីឆ្នាំនោះទេ ប៉ុន្តែវាជាបញ្ហាពេញមួយជីវិតមនុស្ស"។

អង្គការជាសមាជិកនៃសម្ព័ន្ធចាប់ដៃ រួមមានទាំងអង្គការ IJM និង AIM បានកំណត់គោលដៅរបស់ពួកគេលើសពីការចុះបង្ក្រាបតាមផ្ទះបនទៅទៀត។ ដើម្បីកាត់បន្ថយបរិមាណនៃឧស្សាហកម្មជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា ដំបូងពួកគេត្រូវតែកែប្រែច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសសិន។

## តើការងារត្រូវបានបញ្ចប់រួចហើយ ឬទើបតែត្រូវបានចាប់ផ្តើមនៅឡើយទេ?

ដោយប្រៀបធៀបជាមួយភាពយន្តបែបរំជួលចិត្តស្តីអំពីការជួយរំដោះ សិក្ខាសាលាបណ្តុះបណ្តាល លិខិតស្នាម និងនីតិវិធីនានាហាក់បីដូចជាគួរឲ្យធុញទ្រាន់។ ប៉ុន្តែ "ការអភិវឌ្ឍសមត្ថភាព" បែបនេះ (ជាភាសារបស់អង្គការសង្គមស៊ីវិល) គឺជាអ្វី ដែលបានជួយដល់កិច្ចការរំដោះក្មេងស្រីមិនទាន់គ្រប់វ័យឱ្យរួចចេញពីផ្ទះបន និងឈប់រស់នៅតាមដងផ្លូវអស់រយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ ទោះបីជាអំពើពេស្យាចារមនុស្សពេញវ័យក៏ជាអំពើខុសច្បាប់នៅក្នុងប្រទេសក្តី ក៏ឧស្សាហកម្មនេះនៅតែកើនឡើងដែរ ហើយសកម្មជន និងអាជ្ញាធរភាគច្រើនផ្តោតកិច្ចខិតខំប្រឹងប្រែងលើការជួយជនរងគ្រោះមិនទាន់គ្រប់អាយុ។

អ្នកស្រី Christa Sharpe ដែលជាអនុប្រធានផ្នែកថែទាំសកលនៃអង្គការ IJM និងជាអតីតនាយិការបស់ការិយាល័យអង្គការ IJM ប្រចាំប្រទេសកម្ពុជាមានប្រសាសន៍ថា៖ "អ្នកមានប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានបំផ្លាញយ៉ាងខ្លាំងសម្រាប់មនុស្ស ហើយគ្មានច្បាប់ ដើម្បីដាក់ឲ្យអនុវត្តដែរ"។ អ្នកស្រីបានបន្តទៀតថា៖ "វាសឲ្យឃើញយ៉ាងច្បាស់ថា ក្រុមអ្នកចូលចិត្តរួមភេទជាមួយកុមារពីក្រៅប្រទេស និងនៅក្នុងប្រទេស អាចធ្វើអ្វីៗតាមចិត្ត ហើយអាចរួចខ្លួនបាន"។

មន្ត្រីនគរបាលមិនត្រូវបានផ្តល់ធនធាន ឬមានការជំរុញទឹកចិត្ត ដើម្បីធ្វើការងារលើករណីជួញដូរមនុស្សឲ្យល្មមគ្រប់គ្រាន់នោះទេ។ នៅពេលប៉ូលីសចាប់ខ្លួនជនល្មើសបាន ពួកគេធ្វើមិនត្រឹមត្រូវនៅក្នុងដំណើរការច្បាប់ ដោយចំណាយពេលជាច្រើនថ្ងៃក្នុងការដាក់ចេញនូវការចោទប្រកាន់ និងស៊ើបសួរ ហើយចោទសួរជនរងគ្រោះនៅជាមួយជនល្មើសដែលជួញដូរនោះ ដោយឆ្លាំឆ្លង។

ឧត្តមសេនីយ៍ សុខ រស្មី ដែលទទួលបន្ទុកលើផ្នែកសហប្រតិបត្តិការអន្តរជាតិសម្រាប់គណៈកម្មការជាតិប្រយុទ្ធប្រឆាំងការជួញដូរមានប្រសាសន៍ថា៖ "យើងចាំបាច់ត្រូវចាប់ផ្តើមពីចំណុចដែលគ្មានអ្វីសោះ ហើយបង្កើតកម្មវិធីបណ្តុះបណ្តាល ដើម្បីឲ្យក្រុមនគរបាលអាចចាប់ផ្តើមចេះកំណត់អត្តសញ្ញាណជនសង្ស័យ និងកសាងសំណុំរឿងព្រហ្មទណ្ឌដោយជោគជ័យបាន"។ អតីតមន្ត្រីប្រយុទ្ធប្រឆាំងអំពើជួញដូររូបនេះបានកោតសរសើរក្រុមស្ថាប័នគ្រិស្តបរិស័ទនៅប្រទេសកម្ពុជា ក៏ដូចជាអង្គការគ្រិស្តបរិស័ទ ដែលស្មោះត្រង់ក្នុងការ "ចូលរួមចំណែកយ៉ាងសកម្ម" នៅក្នុងបុព្វហេតុនេះ។

ដោយសារតែមានការឆ្លើយតបចំពោះការពង្រឹងច្បាប់ ហើយសេវាកម្មសង្គមត្រូវបានបង្កើនបន្ថែម ប្រជាពលរដ្ឋចាប់ផ្តើមទុកចិត្តលើមន្ត្រីនគរបាលច្រើនជាងមុន ហើយរាយការណ៍លើករណីជួញដូរច្រើនជាងមុនដែរ។ នៅពេលបម្រើការងារនៅក្នុងប្រទេសកម្ពុជាដំបូង កាលពីជាងមួយទសវត្សរ៍មុន អ្នកស្រី Sharpe មានប្រសាសន៍ថា៖ "ចលនាប្រយុទ្ធប្រឆាំងការជួញដូរត្រូវបានដឹកនាំដោយក្រុមអង្គការសង្គមស៊ីវិល ប៉ុន្តែនៅពេលនេះ រដ្ឋាភិបាលដឹកនាំវិញម្តង"។

ដោយមានទំនុកចិត្តថា ប្រព័ន្ធច្បាប់បានរីកចម្រើនប្រសើរឡើង ហើយក្មេងស្រីមិនទាន់គ្រប់អាយុឈប់មានវត្តមាននៅតាមផ្ទះបនទៀតនោះ (អ្នកសិក្សាស្រាវជ្រាវបានរកឃើញថា មានតែ ០.១% ប៉ុណ្ណោះ គឺជាក្មេងស្រីមានអាយុក្រោម ១៥ឆ្នាំ) អង្គការមួយនេះ ដែលបានចាប់ផ្តើមចលនាលុបបំបាត់ការជួញដូរមនុស្សនៅប្រទេសកម្ពុជាបានបញ្ចប់ការងាររបស់ខ្លួន ដែលប្រយុទ្ធប្រឆាំងការជួញដូរផ្លូវភេទកុមារនៅក្នុងឆ្នាំ ២០១៥។ ជំនួសមកវិញ អង្គការ IJM បានចាប់ផ្តើមគម្រោងកម្មវិធីថ្មី ដែលប្រយុទ្ធប្រឆាំងការជួញដូរកម្លាំងពលកម្មនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំមុន ដោយមានគោលដៅផ្តោតលើឧស្សាហកម្ម ដែលផ្អែកលើការបោកបញ្ឆោត ការផ្តល់កម្រៃឈ្នួលតិចតួច និងការប្រព្រឹត្តមិនសមរម្យចំពោះកម្មករ ដែលត្រូវការការងារធ្វើ។

ព្រមពេលជាមួយគ្នានេះដែរ អង្គការ AIM ក៏បន្តការងារកសាងសហគមន៍របស់ខ្លួននៅក្នុងតំបន់ស្វាយប៉ាក ដែលជាភូមិមួយមានប្រជាជនចំនួន ១០,០០០នាក់ ដែលភាគច្រើនជាជនជាតិវៀតណាម។ អ្នករស់នៅជិតខាងជាច្រើននៃព័ន្ធកិច្ចរបស់អង្គការនេះ មានទំនាក់ទំនងជាមួយក្រុមឧក្រិដ្ឋជនវៀតណាម ដែលពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទកុមារនៅកម្ពុជា។ (ការសិក្សាស្រាវជ្រាវមួយរបស់អង្គការសម្ព័ន្ធចាប់ដៃបានរកឃើញថា ជនជាតិវៀតណាមមានចំនួនត្រឹមតែ ៥%នៃចំនួនប្រជាជនកម្ពុជាសរុបប៉ុណ្ណោះ ប៉ុន្តែមានក្មេងស្រីជនជាតិវៀតណាមពី ៦០-៧០% ស្ថិតនៅក្នុងមណ្ឌលថែទាំបន្ទាប់របស់អង្គការ)។

អង្គការ AIM ព្យាយាមដោះស្រាយបញ្ហាឫសគល់ពីដំបូងបំផុត ដែលនាំឲ្យមានការជួញដូរក្មេងស្រីទាំងនោះ។ ប្រសិនបើក្រុមគ្រួសារណាមួយមាន "លេសដោះសារ" ដើម្បីធ្វើពេស្យាកម្មលើកូនស្រីរបស់ខ្លួន នោះអង្គការនឹងព្យាយាមផ្តល់ជូនដំណោះស្រាយបន្ទាន់ ដូចជា៖ ប្រសិនបើគ្មានលទ្ធភាពបញ្ជូនកូនទៅរៀន? ពួកគេអាចចូលរួមក្លឹបកុមារ សាលារៀនក្នុងសហគមន៍ ឬថ្នាក់សិក្សាភាសាអង់គ្លេសសម្រាប់មនុស្សធំរបស់អង្គការ។ ហើយប្រសិនបើមានបញ្ហាបន្ទាន់ផ្នែកវេជ្ជសាស្ត្រ ដែលត្រូវការថវិកាភ្លាមៗ? ពួកគេអាចមកទទួលសេវាកម្មវេជ្ជសាស្ត្រនៅគ្លីនិករបស់អង្គការនេះ ដោយឥតគិតថ្លៃ។ បើគ្មានការងារធ្វើ? អង្គការ AIM នឹងផ្តល់ការងារឲ្យធ្វើនៅទីនោះបាន។ នៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់របស់អង្គការនេះ ពួកគេបង់ប្រាក់បៀវត្សរ៍ឱ្យច្រើនជាងពីរទៅប្រាំដង លើសពីប្រាក់ឈ្នួលមធ្យម ហើយក៏ផ្តល់សេវាកម្មមើលថែទាំកូនដោយឥតគិតថ្លៃដែរ។ អង្គការនេះមានកម្មករជាង ២០០នាក់ ដេរប៉ាក់អាវក្រៅស្ត្រី និងដេរអាវយឺត ដើម្បីលក់នៅហាង Macy's។

ក្នុងខណៈនេះដែរ ក្លឹបហាត់ប្រដាល់សេរីនៅជាប់ដងផ្លូវនោះ ក៏អញ្ជើញពួកមេបន ឈ្មួញកណ្តាលទិញដូរសេវាកម្មផ្លូវភេទ និងអ្នកប្រព្រឹត្តអំពើរំលោភបំពាន មកទទួលការហ្វឹកហាត់ ដោយបន្ថែមការហាត់ប្រាណនោះជាមួយនឹងការពិភាក្សាពីប្រធានបទទាក់ទងនឹងភាពជាបុរស ដែលស្របតាមព្រះហឫទ័យព្រះជាអម្ចាស់។ នៅពេលមនុស្សដែលរស់នៅក្នុងសហគមន៍នោះត្រូវបានចាប់ខ្លួនពីបទជួញដូរ ឬសកម្មភាពឧក្រិដ្ឋដទៃផ្សេងទៀតនោះ អង្គការ AIM នឹងផ្តល់ទីកន្លែងស្នាក់អាស្រ័យ និងផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់ពួកគេនៅមណ្ឌលថែទាំរយៈពេលខ្លី។

លោក Clayton Butler នាយកប្រចាំប្រទេសរបស់អង្គការ AIM ដែលដើរស្វាគមន៍មនុស្សគ្រប់រូបនៅ

តាមផ្លូវរហូតដល់អ្នកលក់ថ្នាំញៀន បានមានប្រសាសន៍ថា៖ "យើងជឿថា ព្រះជាម្ចាស់ចង់ផ្លាស់ប្រែជីវិតមនុស្សគ្រប់រូប ទាំងជនរងគ្រោះ និងអ្នកប្រព្រឹត្តល្មើសដែរ"។ (គាត់សួរជាភាសាខ្មែរថា៖ "លក់អីហ្នឹងមិត្ត?")។ "ពេលខ្ញុំធ្វើការនៅទីនេះកាន់តែយូរ ខ្ញុំមិនមានអារម្មណ៍កាន់តែស្អប់ និងកាន់តែខឹងទេ តែខ្ញុំមានអារម្មណ៍កាន់តែអាណិតវិញ"។ លោក Don Brewster ជាគ្រូគង្វាលជនជាតិអាមេរិក ដែលបានបង្កើតអង្គការ AIM និងផ្លាស់ទៅរស់នៅតំបន់ស្វាយប៉ាកកាលពីឆ្នាំ ២០០៥ មានប្រសាសន៍ថា៖ ការចុះបង្ក្រាបរបស់ប៉ូលីសបានធ្វើឲ្យជនល្មើសជួញដូរព្យាយាមប្រើល្បិចឆ្លាតជាងមុន។ ការជួញដូរជាអាជីវកម្មរកចំណូលបានច្រើននៅប្រទេសមួយនេះ ដែលប្រជាជនភាគច្រើនរកប្រាក់ចំណូលបានត្រឹមតែពីរបីដុល្លារប៉ុណ្ណោះក្នុងមួយថ្ងៃ។ សៀវភៅបញ្ជីកត់ត្រាចំណូលនៅក្នុងផ្ទះបនបង្ហាញថា បើស្ត្រីៗអាចទទួលភ្ញៀវបានពី ១០ ទៅ ២០នាក់ក្នុងមួយយប់ នោះគេអាចរកចំណូលបានល្មមគ្រប់គ្រាន់រហូតដល់ទៅជាងមួយលានដុល្លារក្នុងមួយឆ្នាំ សូម្បីវាជាអាជីវកម្មតូចតាចក្តី។

លោក Brewster មានប្រសាសន៍បន្តថា៖ "នៅពេលណាដែលចលនាប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបានទទួលជោគជ័យ នោះការជួញដូរនឹងវិវត្ត ហើយរីកសុះសាយបន្ថែមទៀត"។ លោកគិតថា ការសិក្សាស្រាវជ្រាវរបស់អង្គការ IJM មិនបានបង្ហាញទិដ្ឋភាពនៃឧស្សាហកម្មកំបាំងមុខមួយនេះឲ្យបានគ្រប់ជ្រុងជ្រោយនោះទេ។

តាមរយៈបណ្តាញនៃក្រុមអ្នកយកការណ៍ និងអ្នកស៊ើបអង្កេតបង្កប់ខ្លួនបានឱ្យដឹងថា អង្គការ AIM បានជួយស្តារក្មេងស្រីមិនទាន់គ្រប់អាយុជាង ១០០នាក់នៅក្នុងរយៈពេលត្រឹមតែពីរបីឆ្នាំកន្លងមកនេះ។ ក្រុមការងារនេះបានសង្កេតឃើញពីរបៀប ដែលជនល្មើសជួញដូរបានផ្លាស់ប្តូរទីតាំងទៅជាកន្លែង ដែលគ្មាននរណាស្មានដឹងមុន (ដូចជា ហាងកាត់សក់សម្រាប់អ្នកមាន ឬទៅតាមផ្សារទំនើបជាដើម) ដោយផ្លាស់ប្តូរស្ត្រីក្មេងៗទៅតាមកន្លែងផ្សេងៗពីគ្នា ឬជួលអ្នកលួចឃ្លាំមើល ឬរង់ចាំប៉ុន្មានខែ ទម្រាំតែពួកគេអាចទុកចិត្តអតិថិជនបានមុនពេលយកស្ត្រីក្មេងៗឱ្យ ឬឱ្យស្ត្រីព្រហ្មចារី ដែលមានតម្លៃថ្លៃ។ វិធីសាស្ត្រទាំងនេះធ្វើឲ្យកាន់តែពិបាកដល់ក្រុមអ្នកស៊ើបអង្កេតក្នុងការកសាងសំណុំរឿង ហើយពិបាកសម្រាប់ក្រុមប៉ូលីសក្នុងការអនុម័តលើការចុះបង្ក្រាប។

ដោយមានការបិទផ្លូវសម្រាប់ជនបរទេសកំសាន្តសប្បាយនៅតាមដងទន្លេសាប ដែលមានបរិយាកាសអាប់អួរលោក Eric Meldrum ដែលជានាយកផ្នែកក្រុមសង្គ្រោះនៃអង្គការ AIM មានការពិបាកទម្រាំតែបានដើរចូលទៅដល់ត្រឹមពីរបីប្លុក មុនពេលចង្អុលបង្ហាញប្រាប់ពីទីតាំងនានា ដែលពួកគេបានចុះបង្ក្រាបពីមុន ហើយព្រមទាំងប្រាប់ពីទីតាំង ដែលពួកគេកំពុងធ្វើការស៊ើបអង្កេតផងដែរ។ គាត់បន្តថា៖ *ភោជនីយដ្ឋានទំនើបមួយនោះ។ នៅខាងក្រោយហាងអ៊ុតសក់មួយនោះ។ វត្តសាលនោះ។* ករណីចុះបង្ក្រាបការជួញដូរផ្លូវភេទច្រើនជាង ៥០% ក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០១៥ បានសម្រេចឡើងតាមរយៈផ្នែករបស់គាត់។

ក្រុមស្រីៗ ដែលពាក់អាវវាលក្លៀក ស្លៀកសំពត់ខ្លីៗ អង្គុយលើកៅអីជ័រនៅខាងមុខហាងម៉ាស្សា ដោយអ្នកខ្លះចុចទូរស័ព្ទដៃ ហើយខ្លះទៀតជជែកគ្នាលេង ខណៈពេលរង់ចាំភ្ញៀវដើរចូល។ នៅហាង ដែលមាន "នារីៗបម្រើ" បុរសអាចចំណាយប្រាក់ ដើម្បីយកស្ត្រីៗទៅរួមភេទនៅខាងក្រៅបាន។ មានបុរសជនជាតិខ្មែរប្រហែលជា ៧០% បានចំណាយប្រាក់ ដើម្បីបានសេវាកម្មផ្លូវភេទ ហើយគេហទំព័រសម្រាប់អ្នកទេសចរណ៍បានណែនាំដល់ជនបរទេសអំពីកន្លែង ដែលពួកគេអាចទៅរកសេវាកម្មនោះ និងប្រាប់ពីរបៀបតថ្លៃ ដោយរៀនប្រាប់ឃ្លាឃ្លោងជាភាសាខ្មែរ ដើម្បីប្រាប់ពីក្បាច់ផ្លូវភេទផ្សេងៗគ្នា ដែលគេចង់បាន។

លោក Meldrum ដែលជាអតីតប៉ូលីសស៊ើបអង្កេតនៅប្រទេសអង់គ្លេសមានប្រសាសន៍ថា៖ "លែងមានក្មេងស្រីមិនទាន់គ្រប់អាយុ (រកស៊ីនៅតាមដងផ្លូវ) ទៀតហើយ... ហើយវាមិនមែនជាកន្លែងសុវត្ថិភាព

សម្រាប់អ្នកចូលចិត្តរួមភេទជាមួយកុមារដែរ។ នោះ គឺជាជោគជ័យមួយដ៏ធំធេង ប៉ុន្តែវាមិនមានន័យថា គ្មានក្មេងស្រីប្រកបរបររកស៊ីផ្លូវភេទនោះទេ"។

## ការយល់ដឹងពីការប៉ះទង្គិចអារម្មណ៍ក្នុងអំឡុងពេលមួយ

វានៅតែមានបញ្ហាជាច្រើន ដែលសូម្បីតែអ្នកជំនាញក៏មិនដឹងអំពីការប៉ះទង្គិចអារម្មណ៍ស្ត្រីៗ និងបុរសៗ ដែលបានរួចផុតពីការជួញដូរនោះមានផង។ នៅពេលអ្នកស្រី Sworn បានឮថា មានស្ត្រីម្នាក់បានធ្វើអត្តឃាតជាច្រើនឆ្នាំ បន្ទាប់ពីបានចាកចេញពីមណ្ឌលសុវត្ថិភាព ហើយបានធ្វើសមាហរណកម្មចូលក្នុងសហគមន៍ខ្លួនវិញ "ដោយជោគជ័យ" (ដោយទទួលបានការងារថ្មី និងរៀបអាពាហ៍ពិពាហ៍) រួចហើយនោះ ប្រធានអង្គការសម្ព័ន្ធចាប់ដៃបានចាប់ផ្តើមការសិក្សាស្រាវជ្រាវដំបូងបំផុតក្នុងពិភពលោកចំពោះជនដែលបានរួចផុតពីអំពើជួញដូរ។ បច្ចុប្បន្ននេះនៅក្នុងឆ្នាំទីប្រាំបី គម្រោងកម្មវិធីមេអំបៅបានតាមដានកត់ត្រាក្រុមមនុស្សដែលបានរួចផុតពីការជួញដូរច្រើនជាង ១២០នាក់ រួមទាំងភាពថប់បារម្ភផ្នែកហិរញ្ញវត្ថុ បញ្ហាផ្នែកអារម្មណ៍ និងការមាក់ងាយដែលពួកគេប្រឈមជាមួយ។ អ្នកស្រី Sworn ដែលមានឯកសារសិក្សាស្រាវជ្រាវទាក់ទងនឹងការជួញដូរជាភាសាអង់គ្លេស និងភាសាខ្មែរជាង ៣,០០០ ច្បាប់នៅក្នុងបណ្ណាល័យមានប្រសាសន៍ថា៖ "យើងមានទំនួលខុសត្រូវក្នុងការស្វែងរកឲ្យឃើញថា តើមានអ្វីកើតឡើងចំពោះស្ត្រីៗទាំងនេះ នៅពេលពួកគេត្រលប់ទៅកាន់សហគមន៍របស់ពួកគេវិញនោះ។ ការជួយរដោះ គឺជាសកម្មភាពមួយ ដែលនាំទៅកាន់ការប្រឹងប្រែងដ៏លំបាកពេញមួយជីវិត"។ នៅឯមណ្ឌល Pleroma សម្រាប់ស្ត្រីវ័យក្មេងក្នុងភូមិនៃតំបន់ជាយក្រុង ដែលមានមនុស្សស្គាល់ច្រើន សំឡេងរត់លេងដោយជើងទទេរលើទីធ្លាក្រាលស៊ីម៉ង់ និងសំណើចក្អាកក្អាយយ៉ាងរំពងនៅទីធ្លាដែលមានរបងព័ទ្ធជុំវិញ មានកុមារីចំនួន ២៤នាក់ ដែលភាគច្រើនមានអាយុពី ៨-១៥ឆ្នាំ និងកំពុងលេងសប្បាយ មុនពេលញ៉ាំអាហារពេលល្ងាច។ កុមារីអាយុ ១៨ ឆ្នាំម្នាក់និយាយថា៖ "ខ្ញុំយល់ថា នៅទីនេះគេឲ្យតម្លៃខ្ញុំ។ ខ្ញុំមានតម្លៃ ជាមនុស្សពិសេស និងសំខាន់"។ នាងព្រួយបារម្ភពីការ ដែលនាងនឹងត្រូវចាកចេញពីមិត្តភក្តិ ហើយត្រលប់ទៅផ្ទះវិញនៅពេលពីរបីសប្តាហ៍ខាងមុខ។ នាងបានបន្តទៀតថា៖ "មានមនុស្សជាច្រើនលើកទឹកចិត្តខ្ញុំឲ្យប្រឈមមុខនឹងបញ្ហា ហើយគិតពិចារណាពីអនាគតរបស់ខ្ញុំ"។ ស្ត្រីវ័យក្មេងទាំងអស់នៅមណ្ឌល Pleroma គឺជាអ្នកដែលបានរួចផុតពីការជួញដូរផ្លូវភេទ ឬការចាប់រំលោភ ប៉ុន្តែមិនមែនតែប៉ុណ្ណឹងនោះទេ។ ស្ត្រីទាំងនេះភាគច្រើនត្រូវបានបង្ខំឲ្យឈប់ទៅរៀន ដើម្បីធ្វើការងារ ហើយត្រូវបានទទួលរងនូវការរំលោភបំពាន ឬការមិនយកចិត្តទុកដាក់ពីសំណាក់ឪពុកម្តាយរបស់ខ្លួន ដែលមានភាពតានតឹងផ្លូវចិត្តខ្លាំង។

អ្នកស្រី ង៉េត គឹមសាង ជាមន្ត្រីផ្នែកសង្គមកិច្ចម្នាក់នៃមណ្ឌល Pleroma មានប្រសាសន៍ថា៖ "វាជាការពិបាកសម្រាប់ស្ត្រីវ័យក្មេងទាំងនេះ ដែលបានជួបនូវហេតុការណ៍ប៉ះទង្គិចអារម្មណ៍ជាច្រើនផ្ទួនៗគ្នានៅក្នុងជីវិតរបស់ពួកគេ។ ពួកគេមិនងាយទុកចិត្តមនុស្សទេ ហើយអារម្មណ៍របស់ពួកគេបង្ហាញចេញមកខាងក្រៅគ្រប់ពេល។ ខ្ញុំសួរពួកនាងថា៖ "តើកូននឹងសុំអ្វីពីព្រះជាម្ចាស់?" ព្រោះមានតែទ្រង់ប៉ុណ្ណោះ ទើបគួរជាទីទុកចិត្តបានជានិច្ច"។ មណ្ឌលសុវត្ថិភាពគ្រិស្តបរិស័ទមួយចំនួនណែនាំដំណឹងល្អនៅក្នុងគម្រោងកម្មវិធីរបស់ពួកគេ ប៉ុន្តែពួកគេមិនទាមទារឲ្យស្ត្រីវ័យក្មេងៗទាំងនោះទៅចូលរួមនៅក្នុងក្រុមជំនុំ ឬក្លាយខ្លួនជាគ្រិស្តបរិស័ទនោះទេ។ ទោះយ៉ាងនេះក្តី មានស្ត្រីវ័យក្មេងជាច្រើនបានស្គាល់ព្រះជាម្ចាស់ផងដែរ។ ជំនឿកម្មផលបែបពុទ្ធសាសនាដាក់បន្ទុកខ្លាំងលើជនរងគ្រោះ។ អ្នកស្រី Hannah Burkle ដែលជានាយិកាប្រចាំប្រទេសនៃអង្គការ Rapha House ដែលបើកមណ្ឌលសុវត្ថិភាពនៅទីក្រុងសៀមរាប និងបាត់ដំបង ដែលជាទីក្រុងធំៗនៃប្រទេសកម្ពុជា

មានប្រសាសន៍ថា៖ "គេធ្លាប់ប្រាប់ពួកនាងថា ដោយសារតែអ្វី ដែលពួកគេធ្វើកាលពីជាតិមុន ទើបធ្វើឱ្យពួកគេជួបរឿងអភ័ព្វ។ ជាពិសេសកម្មពៀរ ដែលជំពាក់បំណុលគេមិនសង ដូច្នេះជាញឹកញាប់ស្ត្រីវ័យក្មេងទាំងនោះត្រូវធ្វើការរកប្រាក់សង ឬដើម្បីលោះខ្លួនឯង ពីព្រោះពួកនាងមានអារម្មណ៍ថា ពួកនាងជំពាក់កម្មដល់ក្រុមជួញដូរ ឬឪពុកម្ដាយរបស់ខ្លួន"។

ដោយប្រៀបធៀបទៅនឹងបន្ទុកបែបនោះ ព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាត្រូវបានប្រទានមកក្នុងលក្ខណៈជាដំណឹងល្អដែលផ្លាស់ប្រែជីវិតរស់នៅ។ ជនរួចផុតពីការជួញដូរជាច្រើននាក់បាននិយាយថា ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ជារឿងដ៏អស្ចារ្យបំផុត ដែលពួកនាងបានយល់ដឹងនៅក្នុងដំណើរការព្យាបាលឱ្យជាសះស្បើយឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេសឹងតែគ្រប់ៗគ្នានឹងត្រឡប់ទៅកាន់ស្រុកកំណើតរបស់ខ្លួនវិញ ហើយជំនឿថ្មីដែលពួកគេមាន នឹងធ្វើឲ្យពួកគេក្លាយជាអ្នកកាន់សាសនាភាគតិច។ លោក Burkle មានប្រសាសន៍ថា៖ "យើងបង្រៀនពួកនាងអំពីរបៀបដែលព្រះយេស៊ូ និងនាងម៉ារីត្រូវបានគេបដិសេធ មិនគ្រាន់តែបង្រៀនអំពីព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ"។

អង្គការ Rapha House មានស្ត្រីវ័យក្មេងជាង ៧០នាក់នៅក្នុងមណ្ឌលសុវត្ថិភាពពួកគេនៅឯក្រុងបាត់ដំបង ដែលជាក្រុងធំជាងគេទីបីនៅប្រទេសកម្ពុជា។ គម្រោងកម្មវិធីនៃអង្គការផ្ដល់ជូនការថែទាំបែបឯកទេស ដោយមានដាក់តាំងនូវទូកមានពណ៌ចម្រុះនៅខាងក្រោយមណ្ឌល ដែលតុបតែងជាទីធ្លានៃការព្យាបាលបែបសិល្បៈនៅក្នុងមណ្ឌលសម្រាប់ស្ត្រីវ័យក្មេងដែលមានតម្រូវការពិសេសទាំងនោះ (រាប់តាំងពីជំងឺអូទីហ្ស៊ឹម រហូតដល់វិបត្តិខួរក្បាលដោយសារការប៉ះទង្គិច) អាចទទួលបានការព្យាបាលផ្នែកសរីរាង្គ ព្រមទាំងទទួលការបង្រៀនអំពីការដាំដុះ ការដុតនំ និងជំនាញបំនិនជីវិតដទៃទៀត។

ត្រឡប់មកទីក្រុងភ្នំពេញវិញ បុគ្គលិកនៅឯមណ្ឌលស្ដារឡើងវិញនៃអង្គការ AIM ដែលជាកន្លែង ដែលជនរងគ្រោះត្រូវបានរំដោះចេញពីអគារប៉ូលឌីញនោះ ហើយត្រូវបានបញ្ជូនទៅអង្គការនេះ កំពុងរៀនភាសាគ ដើម្បីអាចប្រាស្រ័យទាក់ទងជាមួយកុមារគថ្លង់ផ្សេងទៀត ដែលស្នាក់នៅទីនោះ។ មណ្ឌលអង្គការនេះក៏ស្វាគមន៍ទទួលយកជនរងគ្រោះដោយការជួញដូរ ដែលមានកូនក្នុងបន្ទុកខ្លួនផងដែរ ដោយជួយមើលថែទាំទារក និងកូនក្មេងតូចៗ ខណៈពេលម្ដាយៗវ័យជំទង់របស់ទារកទាំងនោះទៅរៀននៅសាលា។

## ប្រឈមមុខជាមួយអនាគតដោយជំនឿ

ប្រទេសកម្ពុជាបានរីកចម្រើនជាដុំកំភួនក្នុងការកាត់បន្ថយចំពោះការជួញដូរផ្លូវភេទកុមារក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ ប៉ុន្តែនៅពេលការជួញដូរវិវត្តខុសពីមុន វាបង្កឲ្យមានឧបសគ្គប្រឈមថ្មីៗផងដែរ ដូចជាអំពើឧក្រិដ្ឋលាក់កំបាំងជាងមុន ការឆ្លងដែន និងការផ្ដល់សេវាកម្មតាមប្រព័ន្ធអ៊ីនធើណិតដល់ជនរំលោភកុមារ។ លោកជំទាវ ជូ ប៊ុនអេង ជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មជាតិប្រយុទ្ធប្រឆាំងការជួញដូរនៃរដ្ឋាភិបាលមានប្រសាសន៍ថា៖ "នៅពេលយើងដោះស្រាយបញ្ហាមួយរួចរាល់ហើយ ជនល្មើសនឹង (បង្កើត) បញ្ហាពីរ ឬបីថែមទៀត"។ អំពើកេងប្រវ័ញ្ច គឺជាបញ្ហា ដែលយើងត្រូវប្រយុទ្ធប្រឆាំងជាបន្តបន្ទាប់ ហើយក៏ជាតេស្តក៏យូរអង្វែងចំពោះការអត់ធ្មត់សម្រាប់ប្រជាជនកម្ពុជាផងដែរ។ ប៉ុន្តែលោកជំទាវមានទំនុកចិត្តថា គ្រិស្តបរិស័ទនឹងនៅតែបន្តចូលរួមចំណែកក្នុងកិច្ចការនេះ។

មន្ត្រីរដ្ឋាភិបាលដែលកាន់ព្រះពុទ្ធសាសនារូបនេះមានប្រសាសន៍នៅក្នុងការិយាល័យរដ្ឋាភិបាលរបស់គាត់ថា៖ "យើងដឹងថា ក្រុមស្ថាប័នគ្រិស្តបរិស័ទពិតជាប្ដេជ្ញាចិត្តជួយដល់ជន ដែលងាយរងគ្រោះប្រាកដ

ណាស់។ ពួកគេធ្វើការងារដោយជំនឿ"។

មន្ត្រីរដ្ឋាភិបាល និងមន្ត្រីនគរបាលមួយចំនួន ដែលមិនមែនជាគ្រិស្តបរិស័ទ បានកោតសរសើរដល់ក្រុមអង្គការគ្រិស្តបរិស័ទ ដែលធ្វើឱ្យមានការរីកចម្រើននៅក្នុងការប្រយុទ្ធប្រឆាំងការជួញដូរនាពេលបច្ចុប្បន្ននេះ។ ចំណែកឯថ្នាក់ដឹកនាំរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល គិតទុកជាមុនអំពីការប្រឈមបន្ទាប់ចំពោះការជួញដូរ ហើយអ្នកស្រី ចាប ចន្ទ្រា នឹងបន្តផ្ដោតលើជំហានបន្ទាប់ខាងមុខទៀតសម្រាប់ស្ត្រីវ័យក្មេងទាំង ២៤នាក់ ដែលស្ថិតនៅក្រោមការថែទាំរបស់អ្នកស្រី។ នៅចុងឆ្នាំមុន មន្ត្រីប្រតិបត្តិនៃមណ្ឌល Pleroma ដែលជាជនជាតិកម្ពុជាកាត់អាមេរិក បានរៀបចំបញ្ជូនស្ត្រីវ័យក្មេងបួននាក់ត្រឡប់ទៅកាន់ក្រុមគ្រួសារនៅស្រុកកំណើតរបស់ពួកគេវិញ ដែលស្ត្រីវ័យក្មេងមួយចំនួននៅក្នុងនោះ បានរស់នៅមណ្ឌលសុវត្ថិភាពនេះរយៈពេលបួនឆ្នាំមកហើយ។ អ្នកស្រី ចន្ទ្រា ដែលជាមន្ត្រីផ្នែកសង្គមកិច្ច ដែលបានធ្វើការជាមួយជនរួចផុតពីការជួញដូរវ័យក្មេងចាប់តាំងពីឆ្នាំ ២០១១ មានប្រសាសន៍ថា៖ "ព្រះជាម្ចាស់បានបញ្ជាក់ប្រាប់ក្នុងចិត្តខ្ញុំយ៉ាងច្បាស់ ហើយរឿងរ៉ាវរបស់ស្ត្រីវ័យក្មេងទាំងនោះ ធ្វើឲ្យខ្ញុំនៅតែបន្តទៅមុខទៀត។ ខ្ញុំចង់ឲ្យពួកគេក្លាយជាអ្នកដឹកនាំនៅក្នុងសហគមន៍របស់គេ។ ខ្ញុំហៅពួកគេថា "លោកជំទាវ" ប្រៀបដូចជា "ពួកគេគឺជាជនដ៏ឧត្ដម ហើយពួកគេនឹងបង្រៀនអ្នកដទៃ។ ខ្ញុំចង់ឲ្យពួកគេក្លាយជាមេធាវី និងវេជ្ជបណ្ឌិត។ ពួកគេ គឺជាអនាគតរបស់យើង"។